# ការថែទាំសុខភាពផ្នែកពន្យារកំណើត និងការយកកូនចេញសម្រាប់យុវវ័យ

## សេវាកម្មទូទៅ

### គ្លីនិកពិនិត្យសុខភាពយុវវ័យ និងមនុស្សពេញវ័យនៅក្មេងរបស់មន្ទីរពេទ្យកុមារនៃទីក្រុង LA (Children's Hospital LA Teen & Young Adult Health Clinic)



**គេហទំព័រ៖ https://www.chla.org/teenage-and-young-adult-health-clinic**

សេវាកម្មទាក់ទងទៅនឹងការថែទាំផ្នែកជំងឺហ៊ីវ (HIV) កង្វល់ផ្នែករដូវនិងរោគស្ត្រី សុខភាពបន្តពូជនិងមធ្យោបាយពន្យារកំណើតនានា រួមមានទាំងមធ្យោបាយពន្យារកំណើតដែលដំណើរការរយៈពេលវែងប៉ុន្តែអាចវិលត្រឡប់ថយក្រោយវិញបាន ហើយនិងការថែទាំសុខភាពអ្នកដែលបានប្តូរភេទខុសពីកំណើតផងដែរ **នៅទីតាំង Wilshire កណ្តាល និងតំបន់ប្រជុំជនជាតិកូរ៉េ (Mid-Wilshire/Koreatown)។**



### មណ្ឌលថែទាំសុខភាព Eisner (Eisner Health)

**គេហទំព័រ៖ https://www.eisnerhealth.org**

មានផ្តល់សេវាកម្មថែទាំសុខភាពចាំបាច់ សេវាកម្មថែទាំសុខភាពកុមារ និងសេវាកម្មថែទាំសុខភាពផ្លូវភេទជូនដល់អ្នកជំងឺគ្រប់អាយុ រួមមានទាំងសេវាកម្មរៀបចំផែនការគ្រួសារ ការធ្វើតេស្តនិងការព្យាបាលជំងឺឆ្លងតាមផ្លូវភេទ (STI) ហើយនិងការធ្វើតេស្តពិនិត្យមើលថាមានផ្ទៃពោះឬទេ ផងដែរ។ **មានទីតាំងនៅកណ្តាលទីក្រុង LA (Downtown LA) និងតំបន់ San Fernando Valley។**

### មណ្ឌលសុខភាពរបស់ស្ត្រី FPA (FPA Women's Health)

**គេហទំព័រ៖ https://www.fpawomenshealth.com**

ដោយមានទីតាំងជាច្រើននៅទូទាំងខោនធី មណ្ឌលសុខភាព FPA ផ្តល់សេវាកម្មទាក់ទងទៅនឹងការថែទាំផ្នែកការយកកូនចេញ ការធ្វើតេស្តនិងការព្យាបាលជំងឺឆ្លងតាមផ្លូវភេទ ហើយនិងជម្រើសផ្នែកពន្យារកំណើតជាច្រើនប្រភេទ ផងដែរ។ **មានផ្តល់ជូនការដាក់ពេលកំណត់ណាត់ជួប តាមប្រព័ន្ធអនឡាញ។**



County of Los Angeles Public Health

## មណ្ឌលសុខភាព Her Smart Choice



**គេហទំព័រ៖** https://hersmartchoice.com/

ក្លីនិកផ្នែកការយកកូនចេញឯកជន**នៅក្នុងតំបន់** Los Angeles **ដែលមានទីតាំងចំនួន ប្រាំពីរកន្លែង**។ ក្លីនិកនេះផ្តល់មធ្យោបាយពន្យារកំណើត ការយកកូនចេញដោយប្រើប្រាស់ថ្នាំពេទ្យ (medication abortion) ហើយនិងការធ្វើតេស្តនិងការព្យាបាលជំងឺឆ្លងតាមផ្លូវភេទ ផងដែរ។ **មានផ្តល់ជូនការដាក់ពេលកំណត់ណាត់ជួប តាមប្រព័ន្ធអនឡាញ**។

## ក្លីនិក Planned Parenthood សម្រាប់តំបន់ Los Angeles

**គេហទំព័រ៖** https://www.plannedparenthood.org/planned-parenthood-los-angeles

ដោយមាន**ទីតាំងនៅទូទាំងខោនធី LA** ក្លីនិក Planned Parenthood សម្រាប់តំបន់ LA ផ្តល់ជូនសេវាកម្មផ្នែកសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ រួមមានទាំងការធ្វើតេស្តនិងការព្យាបាលជំងឺឆ្លងតាមផ្លូវភេទ មធ្យោបាយពន្យារកំណើត ការធ្វើតេស្តពិនិត្យរកមើលជំងឺមហារីកនៅនឹងកស្បូន (pap tests) ការយកកូនចេញ ហើយនិងការចាក់ថ្នាំបង្ការផ្សេងៗ ផងដែរ។ **មានផ្តល់ជូនការដាក់ពេលកំណត់ណាត់ជួប តាមប្រព័ន្ធអនឡាញ ហើយនិងមានយុវវ័យជាអ្នកឯកទេសសម្រាប់ការដាក់ពេលកំណត់ណាត់ជួប តាមទូរស័ព្ទ ផងដែរ**។

## ក្លីនិក Planned Parenthood សម្រាប់តំបន់ Pasadena និងតំបន់ San Gabriel Valley

**គេហទំព័រ៖** https://www.plannedparenthood.org/planned-parenthood-pasadena-san-gabriel-valley

ក្លីនិកទាំងឡាយមាន**ទីតាំងនៅប៉ែកខាងកើតនៃខោនធី LA**។ មានផ្តល់ការពិនិត្យសុខភាពការពារទុកជាមុន មធ្យោបាយពន្យារកំណើត ការធ្វើតេស្តនិងការព្យាបាលជំងឺឆ្លងតាមផ្លូវភេទ ការយកកូនចេញ ហើយនិងថ្នាំសម្រាប់ទប់ស្កាត់ជំងឺហ៊ីវ (HIV) ក្រោយពេលប៉ះពាល់ទៅនឹងមេរោគរួច (PostExposure Prophylaxis/PEP) និងថ្នាំសម្រាប់ទប់ស្កាត់ជំងឺហ៊ីវ (HIV) មុនពេលប៉ះពាល់ទៅនឹងមេរោគ (Pre-Exposure Prophylaxis/PrEP) ផងដែរ។ **មានផ្តល់ជូនការដាក់ពេលកំណត់ណាត់ជួប តាមប្រព័ន្ធអនឡាញ ហើយនិងមានយុវវ័យជាអ្នកឯកទេសសម្រាប់ការដាក់ពេលកំណត់ណាត់ជួប តាមទូរស័ព្ទ ផងដែរ**។

## មណ្ឌលសុខភាពគ្រួសារ Westside (Westside Family Health Center)

**គេហទំព័រ៖** https://www.wfhcenter.org/

**មានទីតាំងនៅក្នុងទីក្រុង Culver City** មណ្ឌលសុខភាពគ្រួសារ Westside ផ្តល់ជូនសេវាកម្មផ្នែកសុខភាពបន្តពូជ រួមមានទាំងការរៀបចំផែនការគ្រួសារ និងការថែទាំផ្នែករោគស្ត្រី ដែលក្នុងនោះមានមធ្យោបាយពន្យារកំណើត ការធ្វើតេស្តពិនិត្យមើលថាមានផ្ទៃពោះឬទេ ការធ្វើតេស្តនិងការព្យាបាលជំងឺឆ្លងតាមផ្លូវភេទ ហើយនិងសេវាកម្មផ្នែកការបញ្ជូនឈ្មោះ ផងដែរ។

## ក្លីនិកសុខភាពគ្រួសារ Venice (Venice Family Clinic)

**គេហទំព័រ៖** https://venicefamilyclinic.org/

ក្លីនិកសុខភាពគ្រួសារ Venice មាន**ទីតាំងក្លីនិកជាច្រើនកន្លែងនៅតំបន់ប៉ែកខាងលិចនៃទីក្រុង LA និងនៅក្នុងតំបន់ South Bay** ផងដែរ ហើយមានផ្តល់ទីប្រឹក្សាផ្នែកការពន្យារកំណើត ការថែទាំផ្នែកផ្ទៃពោះ ការធ្វើតេស្តពិនិត្យសុខភាពផ្លូវភេទ ហើយនិងការព្យាបាលដោយដាក់បន្ថែមអ័រម៉ូន (hormonal therapy) ផងដែរ។



COUNTY OF LOS ANGELES
Public Health

# សេវាកម្មពិសេស

## កម្មវិធីជីវិតក្រុមគ្រួសារនៃមនុស្សវ័យជំទង់របស់សេវាកម្មថែទាំសុខភាព Alta Med (Alta Med Health Services - Adolescent Family Life Program)

**គេហទំព័រ៖ https://www.altamed.org/youth-services**

ភ្ជាប់**យុវវ័យដែលមានផ្ទៃពោះ និងឪពុកម្តាយដែលមានអាយុក្រោម 22 ឆ្នាំ** ទៅនឹងអ្នកគ្រប់គ្រងសំណុំរឿង (case manager) ម្នាក់ ដើម្បីផ្តោតគំនិតទៅលើការអភិវឌ្ឍន៍របស់យុវវ័យដែលវិជ្ជមាន (ដូចជាការកំណត់អត្តសញ្ញាណនៃចំណុចខ្លាំង ការស្រាវជ្រាវរកគុណសម្បត្តិ ការចាត់តាំងគោលដៅ និងការបង្កើតជំនាញ ជាដើម)។

## មជ្ឈមណ្ឌលសម្រាប់អ្នក LGBT នៃទីក្រុង Los Angeles (Los Angeles LGBT Center)

**គេហទំព័រ៖ https://lalgbtcenter.org/**

មានផ្តល់ជូននូវ**សេវាកម្មជាច្រើនប្រភេទសម្រាប់យុវវ័យដែលជាស្រីស្រឡាញ់ស្រី (lesbian) ជាប្រុសស្រឡាញ់ប្រុស (gay) ជាអ្នកស្រឡាញ់ទាំងពីរភេទ (bisexual) ជាអ្នកប្តូរភេទខុសពីកំណើត (transgender) ជាអ្នកមិនស្រឡាញ់ភេទផ្ទុយគ្នា (queer) និងអ្នកមិនច្បាស់អំពីភេទរបស់ខ្លួន (questioning)** រួមមានទាំងការថែទាំសុខភាពបន្ទាន់ ការថែទាំសុខភាពសម្រាប់ការផ្លាស់ប្តូរភេទខុសពីកំណើត ហើយនិងសេវាកម្មផ្នែកទីលំនៅនិងផ្នែកបញ្ជូនឈ្មោះ ផងដែរ។ មានគ្លីនិកចំនួន ប្រាំបីទីតាំងផ្សេងគ្នានៅទូទាំងទីក្រុង ដោយរួមមានទាំងមជ្ឈមណ្ឌលសម្រាប់យុវវ័យផងដែរ។

## គ្លីនិករបស់មជ្ឈមណ្ឌលថែទាំសុខភាពកុមារ (Pediatric Medical Hub Clinics)

**គេហទំព័រ៖ https://dhs.lacounty.gov/medical-hubs/our-services/home/**

គ្លីនិករបស់មជ្ឈមណ្ឌលថែទាំសុខភាពនៃខោនធី Los Angeles (Los Angeles County Medical Hub Clinics) ផ្តល់ការថែទាំសុខភាពដែលមានគុណភាពខ្ពស់ ហើយដែលមានការសម្របសម្រួលត្រឹមត្រូវ រួមមានទាំងការថែទាំសុខភាពបន្ទាន់ សម្រាប់**មនុស្សវ័យក្មេងទាំងឡាយដែលមានការពាក់ព័ន្ធជាមួយនឹងនាយកដ្ឋានសេវាកម្មសម្រាប់កុមារនិងក្រុមគ្រួសារ (Department of Children and Family Services/DCFS)**។ មានមជ្ឈមណ្ឌលចំនួន ប្រាំពីរទីតាំង៖

- **មណ្ឌលថែទាំសុខភាព Harbor-UCLA (Harbor-UCLA Medical Center)**
- **មណ្ឌលសុខភាពក្នុងតំបន់ High Desert (High Desert Regional Health Center)**
- **មណ្ឌលសម្រាប់អ្នកជំងឺមិនសម្រាកព្យាបាល MLK Jr. (MLK Jr. Outpatient Center)**
- **មណ្ឌលថែទាំសុខភាព LAC+USC (LAC+USC Medical Center)**
- **គ្លីនិកនៅតំបន់ San Gabriel Valley ប៉ែកខាងកើត (East San Gabriel Valley Clinic)**
- **មណ្ឌលថែទាំសុខភាព Olive View-UCLA (Olive View-UCLA Medical Center)**
- **មន្ទីរពេទ្យកុមារនៃទីក្រុង LA (Children's Hospital LA/CHLA)**



# មណ្ឌលសុខភាពនៅតាមសាលារៀន

គ្លីនិកទាំងឡាយខាងក្រោមនេះ**មានទីតាំងនៅខាងក្នុងសាលារៀន** ហើយអាចមានការប្រើប្រាស់បានដោយសិស្សនៅតាមសាលារៀនទាំងនោះ តែប៉ុណ្ណោះ។ គ្លីនិកទាំងនេះមួយចំនួនផ្តល់សេវាកម្មជូនដល់សមាជិកក្រុមគ្រួសាររបស់សិស្សទាំងឡាយដែលកំពុងសិក្សានៅទីនោះ ផងដែរ។

## គ្លីនិកនៅតាមសហគមន៍ដែលមានភាពជាដៃគូ (Community Clinic Partnerships)

- គ្លីនិកសម្រាប់យុវវ័យនៃវិទ្យាល័យទីក្រុង Los Angeles របស់មណ្ឌលថែទាំសុខភាពផ្នែកកុមារនិងក្រុមគ្រួសារ Eisner (Eisner Pediatric and Family Medical Center's Los Angeles High School Teen Clinic)
  **គេហទំព័រ៖** www.eisnerhealth.org
- មណ្ឌលថែទាំសុខភាព Harbor-UCLA នៅវិទ្យាល័យ Gardena (Harbor-UCLA at Gardena High School)
  **គេហទំព័រ៖** https://bit.ly/gardenahscommclinic
- មណ្ឌលថែទាំសុខភាព Roosevelt (Roosevelt Wellness Center)
- គ្លីនិកសម្រាប់យុវវ័យ Valley ដែលមានទីតាំងនៅក្នុងវិទ្យាល័យ Kennedy (Valley Teen Clinic located in Kennedy High School)
  **គេហទំព័រ៖** www.valleycommunityhealthcare.org



## មណ្ឌលថែទាំសុខភាពរបស់ LAUSD និង LA Trust (LAUSD and LA Trust Wellness Centers)

**គេហទំព័រ៖** https://achieve.lausd.net/wellnesscenters

មណ្ឌលថែទាំសុខភាពសម្រាប់សិស្សនិងក្រុមគ្រួសារ LA Trust (LA Trust Student & Family Wellness Centers) មានទីតាំងនៅខាងក្នុងសាលារៀនទាំងឡាយខាងក្រោមនេះ៖

- វិទ្យាល័យ Belmont
- វិទ្យាល័យ Carson
- វិទ្យាល័យ Crenshaw
- មណ្ឌលសិក្សា Elizabeth (Elizabeth Learning Center)
- វិទ្យាល័យ Fremont
- អនុវិទ្យាល័យ Gage
- វិទ្យាល័យ Garfield
- វិទ្យាល័យ Hollywood
- វិទ្យាល័យ Jefferson
- អនុវិទ្យាល័យ Maclay
- វិទ្យាល័យ Manual Arts
- មណ្ឌលថែទាំសុខភាព North Hills នៅវិទ្យាល័យ James Monroe
- វិទ្យាល័យ Washington Prep

## មណ្ឌលថែទាំសុខភាពទាំងឡាយរបស់នាយកដ្ឋានសុខភាពសាធារណៈនៃខោនធី LA (LA County Department of Public Health Wellbeing Centers)

ដោយមានទីតាំងនៅក្នុងបរិវេណវិទ្យាល័យជាច្រើន មណ្ឌលថែទាំសុខភាពទាំងឡាយគឺជាទីកន្លែងមានការទទួលស្វាគមន៍ដែលសិស្សអាចបន្ធូរអារម្មណ៍បាន ហើយនិងអាចទទួលបានព័ត៌មាននិងសេវាកម្មផ្សេងៗសម្រាប់ប្រធានបទផ្នែកសុខភាពជាច្រើនប្រភេទ។ មានអារម្មណ៍តានតឹងឬ? មានអារម្មណ៍សោកសៅឬ? ចង់ដឹងបន្ថែមទៀតអំពីការទប់ស្កាត់ជំងឺឆ្លងតាមផ្លូវភេទ (STI) ឬ? ចង់ពិភាក្សាជាមួយនឹងនរណាម្នាក់អំពីការទំនាក់ទំនងរបស់អ្នកជាមួយនឹងអ្នកដទៃឬ? ត្រូវការព័ត៌មានបន្ថែមអំពីថ្នាំបំបាត់ការឈឺចាប់ដែលអាចញៀនបានប្រភេទ Fentanyl ឬក៏អំពីរបៀបជួយដល់មិត្តភក្តិម្នាក់ឱ្យកាត់បន្ថយការជក់បារីអេឡិចត្រូនិច (vaping) ឬ? ចង់ដឹងថាតើអាចរកថ្នាំពន្យារកំណើតបែបបន្ទាន់នៅទីណាឬ?

**ស្វែងយល់ថាតើសាលារៀនរបស់អ្នកមានមណ្ឌលថែទាំសុខភាពឬទេ ដោយសាកសួរទៅកាន់ការិយាល័យធំរបស់សាលារៀនអ្នក ឬដោយការទូរស័ព្ទទៅកាន់ Ellen Sanchez នៃនាយកដ្ឋានសុខភាពសាធារណៈ (Department of Public Health) តាមរយៈលេខ (626) 299-4502។**

---

*នេះគឺជាឯកសារធនធានដែលមានការធ្វើបច្ចុប្បន្នកម្មជាប្រចាំ ហើយមិនមែនជាឯកសារបញ្ជីដែលពេញលេញនោះទេ។ ប្រសិនបើអ្នកចង់ឱ្យមានការដាក់បញ្ចូលព័ត៌មានទាក់ទងទៅនឹងមណ្ឌលសុខភាពនៅតាមសាលារៀនរបស់អ្នក ឬចង់ធ្វើឱ្យព័ត៌មានបានត្រឹមត្រូវទាន់ហេតុការណ៍នោះ សូមធ្វើការទាក់ទងមកកាន់យើងខ្ញុំតាមរយៈអ៊ីម៉ែល៖ owh@ph.lacounty.gov។*

COUNTY OF LOS ANGELES
Public Health

# ធនធានទាក់ទងទៅនឹងសុខភាពបន្តពូជ

## Pocket Guide LA

**គេហទំព័រ៖** https://www.pocketguidela.org/

គេហទំព័រនេះផ្តល់ជូននូវព័ត៌មានដែលអាចអនុវត្តចំពោះស្ថានភាពជាច្រើនបានទាក់ទងទៅនឹងគ្លីនិកនៅក្នុងទីក្រុង LA ដែលផ្តល់សេវាកម្មផ្នែកសុខភាពបន្តពូជដល់យុវវ័យ។ គេហទំព័រនេះក៏មានព័ត៌មានទាក់ទងទៅនឹងការរក្សាការសម្ងាត់ និងសិទ្ធិរបស់យុវវ័យ ផងដែរ។



## ScarletTeen

**គេហទំព័រ៖** https://www.scarleteen.com

មានផ្តល់ព័ត៌មានទាក់ទងទៅនឹងផ្លូវភេទ និងការទំនាក់ទំនងជាមួយនឹងអ្នកដទៃដែលមានការគិតគូ ដែលពេញលេញ និងដែលមានការគាំទ្រ ជូនទៅដល់ក្មេងជំទង់ និងមនុស្សពេញវ័យដែលមិនសូវមានបទពិសោធន៍ជីវិត។

## TeenSource+

**គេហទំព័រ៖** https://www.teensource.org/

គេហទំព័រមួយដែលធ្វើការអប់រំដល់មនុស្សវ័យក្មេងទាំងឡាយអំពីសុខភាពផ្លូវភេទនិងសុខភាពបន្តពូជ សេវាកម្មមិនគិតថ្លៃដែលរក្សាការសម្ងាត់ដែលពួកគេអាចប្រើប្រាស់បាន ហើយនិងសិទ្ធិរបស់ពួកគេក្នុងការទទួលបានការថែទាំ ការទទួលខុសត្រូវលើសុខភាពរបស់ពួកគេ ព្រមទាំងការបង្កើតការទំនាក់ទំនងជាមួយនឹងអ្នកដទៃដែលប្រកបដោយការគោរព និងការជឿជាក់។



## គម្រោងដើម្បីទទួលបានភាពសមរម្យ និងយុត្តិធម៌ទាក់ទងទៅនឹងសុខភាពបន្តពូជ (Reproductive Health Equity Project)

**គេហទំព័រ៖** https://fosterreprohealth.org/

គម្រោងដើម្បីទទួលបានភាពសមរម្យនិងយុត្តិធម៌ទាក់ទងទៅនឹងសុខភាពបន្តពូជ (RHEP) សម្រាប់យុវវ័យស្ថិតក្រោមការចិញ្ចឹមមើលថែទាំនេះ ភ្ជាប់យុវវ័យដែលស្ថិតក្រោមការចិញ្ចឹមមើលថែទាំ (foster care) ជាមួយនឹងទីភ្នាក់ងារដែលបម្រើការជូនដល់ពួកគេ ដើម្បីលើកកម្ពស់ប្រព័ន្ធដំណើរការផ្សេងៗដែលធ្វើឱ្យមានលក្ខណៈធម្មតា គាំទ្រ និងលើកកម្ពស់ដល់ការមានសិទ្ធិម្ចាស់ការលើរាងកាយ ហើយនិងការយល់ដឹងផ្នែកផ្លូវភេទដែលត្រឹមត្រូវ និងសមរម្យសម្រាប់យុវវ័យទាំងឡាយដែលស្ថិតក្រោមការចិញ្ចឹមមើលថែទាំ។

## Talk With Your Kids

**គេហទំព័រ៖** https://www.talkwithyourkids.org/

គេហទំព័រ Talk With Your Kids ផ្តល់នូវព័ត៌មានសម្រាប់បង្កើតជំនឿចិត្តដល់ឪពុកម្តាយនិងក្រុមគ្រួសារទាំងឡាយ ដើម្បីចាប់ផ្តើមការសន្ទនាដែលសក្តិសមទៅនឹងអាយុ និងដោយផ្អែកទៅលើការពិត ជាមួយនឹងកូនៗរបស់ពួកគេ អំពីការទំនាក់ទំនងជាមួយនឹងអ្នកដទៃ អំពីការរួមភេទ អំពីការលូតលាស់ និងចំណុចជាច្រើនទៀត។



# ធនធានទាក់ទងទៅនឹងច្បាប់ផ្នែកសុខភាពរបស់យុវវ័យ

## មជ្ឈមណ្ឌលជាតិសម្រាប់ច្បាប់របស់យុវវ័យ (National Center for Youth Law)

**គេហទំព័រ៖** https://youthlaw.org/

មជ្ឈមណ្ឌលជាតិសម្រាប់ច្បាប់របស់យុវវ័យ (NCYL) ផ្ដល់មធ្យោបាយ ការបណ្ដុះបណ្ដាល និងធនធានផ្សេងៗជូនដល់យុវវ័យ ឪពុកម្ដាយ និងអ្នកផ្ដល់សេវាកម្មផ្នែកថែទាំសុខភាពទាំងឡាយ ដើម្បីជួយពួកគេក្នុងការស្វែងរកទិសដៅទាក់ទងទៅនឹងបំណងប្រាថ្នាដែលកាន់តែធំជាងមុនរបស់យុវវ័យក្នុងការទទួលបានការលាក់កំបាំងកាន់តែច្រើនទៅនោះ ដែលអាចធ្វើឱ្យដៃគូផ្ដល់ការថែទាំ និងអ្នកផ្ដល់សេវាកម្មផ្នែកថែទាំសុខភាពទាំងឡាយមានអារម្មណ៍ថាពិបាក។

## ច្បាប់ផ្នែកសុខភាពរបស់យុវវ័យ (Teen Health Law)

**គេហទំព័រ៖** https://teenhealthlaw.org/consent/

ឯកសារជំនួយនៅលើគេហទំព័រនេះធ្វើការសង្ខេបអំពីសិទ្ធិរបស់អនីតិជន (ជនមិនទាន់គ្រប់អាយុ) និងភាគីទីបីក្នុងការផ្ដល់ការអនុញ្ញាតចំពោះការថែទាំសុខភាពរបស់អនីតិជននៅក្នុងរដ្ឋ California។

## កម្មវិធីច្បាប់ផ្នែកសុខភាពថ្នាក់ជាតិ (National Health Law Program/NHeLP)

**គេហទំព័រ៖** https://healthlaw.org/resource/resources-for-california-foster-youth-sexual-reproductive-and-mental-health-medi-cal-services/

យុវវ័យដែលជាអ្នកកំពុងស្ថិតក្រោមការចិញ្ចឹមមើលថែទាំ (foster) និងអ្នកដែលធ្លាប់បានស្ថិតក្រោមការចិញ្ចឹមមើលថែទាំពីមុន ហើយដែលជាសមាជិកកម្មវិធីធានារ៉ាប់រង Medi-Cal នោះ អាចទទួលប្រើប្រាស់សេវាកម្មផ្នែកសុខភាពបន្តពូជ ផ្នែកសុខភាពផ្លូវភេទ និងផ្នែកសុខភាពផ្លូវចិត្តជាច្រើនប្រភេទបាន ផងដែរ។ NHeLP បានបង្កើតសំណុំឯកសាររូបភាពក្រាហ្វិកដែលមានផ្ទុកព័ត៌មាន និងតារាងព័ត៌មានការពិតផ្សេងៗក្នុងគោលបំណងជួយដល់យុវវ័យដែលស្ថិតក្រោមការចិញ្ចឹមមើលថែទាំឱ្យយល់បានកាន់តែច្បាស់ជាមុនចំពោះសេវាកម្មផ្សេងៗដែលមានសម្រាប់ផ្ដល់ជូនដល់ពួកគេ តាមរយៈកម្មវិធីធានារ៉ាប់រង Medicaid នៃរដ្ឋ California ដែលអាចអនុវត្តចំពោះស្ថានភាពជាច្រើនបាននោះ។



**សូមស្កេនកូដ QR នេះ សម្រាប់ព័ត៌មានបន្ថែមអំពីការយកកូនចេញ និងការពន្យារកំណើត។**